សេចក្តីព្រាង ១.០

# ជំរើសនៃវិធីសាស្រ្តចំពោះការផ្តល់សេវាជំនួយផ្នែកច្បាប់នៅកម្ពុជា

## រៀបចំសំរាប់ក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌

DANIDA ទីភ្នាក់ងារជំនួយអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសដាណឺម៉ាក
12/9/2011

# មាតិកា

អក្សរកាត់ .......... 3

ផ្នែកសង្ខេប .......... Error! Bookmark not defined.

(i) លំនាំដើម .......... Error! Bookmark not defined.

(ii) របកគំហើញ .......... Error! Bookmark not defined.

(iii) ជំរើសផ្សេងៗ .......... Error! Bookmark not defined.

(iv) អនុសាសន៍ .......... Error! Bookmark not defined.

1. សេចក្តីផ្តើម .......... Error! Bookmark not defined.

1.1 គោលបំណង .......... Error! Bookmark not defined.

1.2 វិធីសាស្រ្ត .......... Error! Bookmark not defined.

2. របកគំហើញ .......... Error! Bookmark not defined.

2.1 បរិយាកាសបច្ចុប្បន្ន .......... Error! Bookmark not defined.

2.2 ការអនុវត្តបច្ចុប្បន្ន .......... Error! Bookmark not defined.

2.3 បញ្ហាប្រឈមក្នុងការផ្តល់សេវាជំនួយផ្នែកច្បាប់ .......... Error! Bookmark not defined.

3. ជំរើសនៃអន្តរាគមចំពោះការផ្តល់សេវាជំនួយផ្នែកច្បាប់ .......... Error! Bookmark not defined.

ជំរើស 1: មិនចាំបាច់មានការផ្លាស់ប្តូរ .......... Error! Bookmark not defined.

ជំរើស 2: បង្កើនចំនួនមេធាវី .......... Error! Bookmark not defined.

ជំរើស 3: ធ្វើនីយត័កម្មនៃសេវាកម្មច្បាប់ពាក់កណ្តាលមេធាវី.......... Error! Bookmark not defined.

ជំរើស 4: បង្កើន/លើកស្ទួយសេវាមិនយកកំរៃ .......... Error! Bookmark not defined.

ជំរើស 5: សេវាជំនួយផ្នែកច្បាប់របស់រដ្ឋាភិបាល .......... Error! Bookmark not defined.

ជំរើស 6: បង្កើន/លើកស្ទួយកន្លែងពិគ្រោះយោបល់ច្បាប់តាមបណ្តាសាកលវិទ្យាល័យ ... Error! Bookmark not defined.

ជំរើស 7: អង្គភាពសម្របសម្រួលសេវាជំនួយផ្នែកច្បាប់ .......... Error! Bookmark not defined.

ជំរើស 8: ការប្រមែប្រមូលធនធានហិរញ្ញវត្ថុ.......... Error! Bookmark not defined.

ជំរើស 9: វិស័យជំនួយផ្នែកច្បាប់នៃមេធាវីឯកជន.......... Error! Bookmark not defined.

DRAFT

ជំរើស 10: ធ្វើទំនាក់ទំនងជាមួយផ្នែកឯកជន ............................ **Error! Bookmark not defined.**

ជំរើស 11: អភិវឌ្ឍន៍ខ្សែទូរសព្ទ័បន្ទាន់ ជំនួយផ្នែកច្បាប់ ............ **Error! Bookmark not defined.**

4. ជំរើសសកម្មភាពផ្សេងៗកំណត់ដោយរាជរដ្ឋាភិបាល ................. **Error! Bookmark not defined.**

5. អនុសាសន៍នានា ........................................................................ **Error! Bookmark not defined.**

ឧបសម្ពន្ធ័ 1: បញ្ជីនៃការពិគ្រោះយោបល់ ............................................ **Error! Bookmark not defined.**

ឧបសម្ពន្ធ័ 2: អនុសាសន៍ស្តីពីជំហានអនុវត្ត ....................................... **Error! Bookmark not defined.**

DRAFT

# ACRONYMS

**ASF** - Avocats Sans Frontieres

**AusAID** - Australian Agency for International Development

**BAKC** - Bar Association of the Kingdom of Cambodia

**CHRAC** - Cambodian Human Rights Action Committee

**CLEC** - Community Legal Education Centre

**CLJR** - Council for Legal & Judicial Reform

**CNP** - Cambodia National Police

**COM** - Council of Ministers

**CWCC** - Cambodian Women Crisis Centre

**DANIDA** - Danish Agency for International Development

**DIHR** - Danish Institute for Human Rights

**EU** - European Union

**EWMI** - East West Management Institute

**GIZ** - Gesellschaft für Internationale Zusammenarbeit

**GS-CLJR** - General Secretariat of the Council for Legal & Judicial Reform

**IBJ** - International Bridges to Justice

**KID** - Khmer Institute of Democracy

**LAC** - Legal Aid of Cambodia

**LSCW** - Legal Support for Children and Women

**LTC** - Lawyer Training Centre

**MOWA** - Ministry of Women's Affairs

**NGO** - Non-government organisation

**RGC** - Royal Government of Cambodia

**UNOHCHR** - United Nations Office of the Commissioner for Human Rights

**USAID** - United States Agency for International Development

DRAFT

# ផ្នែកសង្ខេប

## លំនាំដើម

លេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌(GS-CLJR) បានស្នើសុំទីភ្នាក់ងារជំនួយអភិវឌ្ឍន៍ អន្តរជាតិនៃប្រទេសដាណឺម៉ាក DANIDA ជួយរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ដើម្បីចងក្រងឯកសារស្តីពីជំរើសផ្សេងៗនៃសេវាជំនួយផ្នែកច្បាប់នៅកម្ពុជា ។ សំណើរនេះគឺចង់ឲ្យក្រុមការងារជួបប្រជុំជាមួយដៃគូរពាក់ពន្ធ័ទាំងឡាយដើម្បីជួយស្វែងរកនិងកំណត់វិធីសាស្រ្តមានប្រសិទ្ធភាពហើយអស់ថវិកាតិចដើម្បីធ្វើឲ្យប្រសើរឡើងនូវកិច្ចសម្របសម្រួលសេវាជំនួយផ្នែកច្បាប់ក្នុងប្រទេសកម្ពុជាដែលមានគុណភាព និងអាចគ្របដណ្តប់គ្រប់ភូមិសាស្រ្តទូទាំងព្រះរាជា ណាចក្រកម្ពុជា ។ ឯកសារស្តីពីជំរើសផ្សេងៗនេះផ្អែកលើកិច្ចប្រជុំដៃគូរពាក់ពន្ធ័នានាដែលអ្នក ជំនាញការអមលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌នឹងដាក់បញ្ចូល ដើម្បីត្រៀមរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីជំនួយផ្នែកច្បាប់ ។

## របកគំហើញ

បរិយាកាសបច្ចុប្បន្ននៃកង្វះថវិកានិងចំនួនតិចតួចនៃអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការលើសេវាជំនួយផ្នែកច្បាប់ កំពុងតែធ្វើឲ្យវិស័យសេវាជំនួយផ្នែកច្បាប់ស្ថិតក្នុងស្ថានភាពយ៉ាប់យ៉ឺន បូកផ្សំនិងវិស័យអាទិភាពកំណត់ដោយប្រទេសផ្តល់ជំនួយផងដែរ ។ ស្ថានភាពកង្វះថវិកានេះត្រូវបាន រាជរដ្ឋាភិបាលមើលឃើញ ហើយបានផ្តល់ជំនួយថវិកាខ្លះៗមកឲ្យអង្គភាពសេវាជំនួយផ្នែកច្បាប់របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។ កង្វះទំនុកចិត្តអំពីសមត្ថភាព/លទ្ធភាពរបស់គណៈមេធាវីនៃ ព្រះរាជាណាចក្រកម្ពុជាក្នុងការផ្តល់សេវាទាំងនេះ ត្រូវបានគូសបញ្ជាក់ជាពិសេសគឺនៅថ្នាក់ក្រោម ជាតិ ដូចជានៅតំបន់ខេត្តដាច់ស្រយ៉ាលជាដើម ។ ចំនួនតិចតួចនៃមេធាវីការពារក្តីដោយ មិនយកកំរៃរបស់អង្គការត្រូវបានមើលឃើញជាទូទៅ ហើយក៏ដោយសារតែចំនួនដ៏តិចតួច នៃមេធាវីទូទាំងប្រទេសផងដែរ ជាពិសេសនៅតាមបណ្តាខេត្ត ។ រីឯសេចក្តីត្រូវការចំពោះសេវា ជំនួយផ្នែកច្បាប់គឺធំធេងណាស់ ព្រោះថារាល់បទល្មើសព្រហ្មទណ្ឌ/បទឧក្រឹដ្ឋ ជាពិសេសគឺបទល្មើស ប្រព្រឹត្តដោយអនីតិជនច្បាប់តម្រូវដាច់ខាតឲ្យមានមេធាវី ។ បើគ្មានមេធាវីទេ តុលាការមិនអាចដំណើរ ការកាត់ក្តីបានទេយោងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រមក្តុជា ។

ការយល់ដឹងអំពីតួរនាទីមេធាវី តាមបណ្តាសហាគមជនបទគឺនៅមានកំរិត ។

DRAFT

ការអនុវត្តក្នុងពេលបច្ចុប្បន្នរួមមាន៖

**អង្គការក្រៅរដ្ឋាភិបាល**: NGOsជំនាញផ្នែកច្បាប់គឺជាប្រភពសំខាន់បំផុតក្នុងការផ្តល់សេវាជំនួយផ្នែកច្បាប់ក្នុងប្រទេសកម្ពុជា ទោះបីកំពុងជួបប្រទះវិបត្តិថវិកានិងលក្ខណ្ឌតឹងរឹងនៃម្ចាស់ជំនួយក៏ដោយ វាបាន បង្កើតការលំបាកនានាក្នុងការផ្តល់សេវាជំនួយផ្នែកច្បាប់ទូទៅ ក៏ដូចជាវិស័យអាទិភាព និងតំបន់អាទិភាពផងដែរ ។

**គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា: BAKC** កំពុងតែផ្តល់ជូនសេវាជំនួយផ្នែកច្បាប់ទាំងនេះ បើទោះណាត្រូវបានមើលជាទូទៅថាមិនសូវមានប្រសិទ្ធិភាពក៏ដោយ ។ កង្វះថវិកា និងបញ្ហាពាក់ពន្ធ័ សិទ្ធិទទួល បានថវិកាគឺជាកត្តាបណ្តាលឲ្យកើតវិបត្តិទាំងនេះ ។

**សេវាកម្មច្បាប់ពាក់កណ្តាលមេធាវី: សេវាកម្មច្បាប់ពាក់កណ្តាលមេធាវី ហៅជាភាសាអង់គ្លេសថា Paralegals** កំពុងត្រូវបានអនុវត្តយ៉ាងជោគជ័យនៅតាមបណ្តាសហាគមជនបទដោយក្រុមអង្គការក្រៅ រដ្ឋាភិបាលមួយចំនួន តែទោះជាយ៉ាងណាក្តីក៏ឋានៈផ្លូវការរបស់ពួកគេនៅមិនទាន់ច្បាស់លាស់ នៅឡើយ ។

**កន្លែងពិគ្រោះយោបល់ច្បាប់តាមសាកលវិទ្យាល័យ:** ការពង្រីកកន្លែងសិក្សានិងពិគ្រោះយោបល់ ច្បាប់បានទូលំទូលាយ តែទោះយ៉ាងណាក៏ដោយក៏គុណភាពនិសិត្សនិងការសិក្សានៅមានកំរិត ឯសក្តានុពលគុណភាពនៃជំនួយផ្នែកច្បាប់ក៏មិនអាចដឹងបាន ។

**នគរបាលយុត្តិធម៌:** ច្បាប់តម្រូវឲ្យមន្ត្រីនគរបាលយុត្តិធម៌អនុញ្ញាតជនត្រូវឃាត់ខ្លួនអាចទទួលបានសិទ្ធិមានមេធាវីបន្ទាប់ពីរយៈពេល២៤ម៉ោង តែវាស្ថិតនៅជាទ្រឹស្តី គ្មានការអនុវត្តដដែលព្រោះថាពុំមាន សេវាមេធាវីនៅតាម មូលដ្ឋានជនបទដាច់ស្រយ៉ាលឡើយ ។

**ពន្ធនាគារ:** ពន្ធនាគារបានផ្តល់សិទ្ធិចេញចូលជួបកូនក្តីដល់មេធាវី ហើយក្នុងករណីភាគច្រើនមានបន្ទប់ជួប សម្ភាសធ៍ដាច់ដោយឡែក តែទោះជាយ៉ាងណាក៏ដោយក៏ពុំបានលើកស្ទួយឬផ្តល់ព័ត៌មានអំពីជំនួយផ្នែកច្បាប់ដោយសកម្មឡើយ ។

**តុលាការ និងអយ្យការ:** ស្ថាប័ននេះតែងតែស្នើសុំជំនួយផ្នែកច្បាប់សំរាប់សវនាការចំពោះរឿងឧក្រិដ្ឋនិងក្តីពាក់ពន្ធ័អនីតិជន តែទោះជាយ៉ាងណាក៏ដោយក៏បានត្រឹមដំណាក់ការជំនុំជំរះដើម្បីធ្វើឲ្យនីតិវិធីស្របច្បាប់តែប៉ុណ្ណោះ ។

DRAFT

កត្តារាំងស្ទះក្នុងការផ្តល់សេវាជំនួយផ្នែកច្បាប់:

*ផ្នែកហិរញ្ញវត្ថុ* – ថវិកាមិនគ្រប់គ្រាន់

*ផ្នែកនីតិកម្ម* – ការលំបាកពាក់ពន្ធ័ការបង្កើនចំនួនមេធាវី និងប្រភេទជំនួយផ្នែកច្បាប់ដែលផ្តល់ដោយ អ្នកមិនមែនជាសមាជិកគណៈមេធាវី ដែលជាការតម្រូវដោយច្បាប់នៃគណៈមេធាវី ។

*ផ្នែកនីតិវិធី* – ជំនួយផ្នែកច្បាប់មិនត្រូវបានតម្រូវក្នុងដំណាក់ការស៊ើបសួរនៃរឿងក្តីឡើយ ។ *ផ្នែកគ្រប់គ្រង* – ស្ថាប័នរាជរដ្ឋាភិបាលពុំយល់អំពីការទទួលខុសត្រូវក្នុងកិច្ចការគ្រប់គ្រងទាក់ទងនិងការសម្របសម្រួលឲ្យមានជំនួយផ្នែកច្បាប់។

*ផ្នែកវិជ្ជាជីវៈ* – មេធាវីមួយចំនួនមិនបានប្រតិបត្តិតួនាទីការងារដោយជំហរវិជ្ជាជីវៈគ្រប់គ្រាន់ពេល បំរើសេវាជំនួយផ្នែកច្បាប់ដល់កូនក្តី ។

*អំពើឆបោក និងអំពើពុករលួយ* – មេធាវីក្លែងក្លាយបានធ្វើឲ្យការជឿទុកចិត្តរបស់ប្រជាពលរដ្ឋតាមសហគមជនបទ មកលើសេវាជំនួយផ្នែកច្បាប់ចុះខ្សោយ និងអំពើពុករលួយខ្នាតតូចអាច បណ្តាលឲ្យការចំណាយលើរឿងក្តីកើនឡើងខ្ពស់ ហើយប៉ះពាល់ដល់ជីវភាពពលរដ្ឋក្រីក្រមិនអាច មានលទ្ធភាពចំណាយលើសេវាជំនួយផ្នែកច្បាប់បាន ។

*ផ្នែកវប្បធម៌ និងកង្វះការយល់ដឹងអំពីតួនាទីមេធាវី* – មនុស្សភាគច្រើនពុំបាន យល់ដឹងអំពីភាព ខុសគ្នារវាងមេធាវី និងចៅក្រមឡើយ ហើយតែងតែយល់ថា ពួកគេជាមនុស្សក្រុមតែមួយ ។ ជាលទ្ធផលប្រជាពលរដ្ឋដែលខ្វះការយល់ដឹង បានបដិសេធមិនទទួលយកជំនួយផ្នែកច្បាប់ ហើយ ចំពោះភាគីដែលមានអំណាចទ្រព្យធនបានឆ្លក់យកឱកាសនេះដើម្បីមានប្រៀបយកឈ្នះក្តី ។

## ជំរើសផ្សេងៗ

ជំរើសសំរាប់អន្តរាគមន៍ក្នុងការផ្តល់សេវាជំនួយផ្នែកច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជារួមមាន:

**មិនចាំបាច់មានការផ្លាស់ប្តូរ:** រក្សាទុកការអនុវត្តនាពេលបច្ចុប្បន្ន

**បង្កើនចំនួនមេធាវី: ចំនួនមេធាវីជាពិសេសតាមខេត្តគួរត្រូវបង្កើន អត្រាកំណត់ដោយគណៈមេធាវី**

DRAFT

ធ្វើនីយ័តកម្មសេវាកម្មច្បាប់ពាក់កណ្តាលមេធាវី: សេវាកម្មច្បាប់ពាក់កណ្តាលមេធាវីត្រូវបានកំណត់និយមន័យ តម្រូវការអប្បរមា និងសមត្ថភាពច្បាស់លាស់ក្នុងការធ្វើកិច្ចការជាផ្លូវការក្នុងវិស័យ យុត្តិធម៌របស់បុគ្គលដែលអនុវត្តសេវាកម្មច្បាប់ពាក់កណ្តាលមេធាវីនេះ ។

លើកតំកើងសេវាមិនយកកំរៃ: បង្កើតលក្ខណ្ឌដើម្បីលើកស្ទួយសេវាមិនយកកំរៃក្នុងប្រទេសកម្ពុជា។

សេវាជំនួយផ្នែកច្បាប់របស់រដ្ឋាភិបាល: រាជរដ្ឋាភិបាលផ្តល់ថវិកាដល់មេធាវីដើម្បីផ្តល់ជំនួយផ្នែកច្បាប់នៅគ្រប់ខេត្ត/ក្រុងទាំងអស់ ។

លើកស្ទួយកន្លែងពិគ្រោះយោបល់ច្បាប់តាមសាកលវិទ្យាល័យ: អនុញ្ញាតឲ្យមានការបង្កើតកន្លែងពិគ្រោះយោបល់ច្បាប់តាមសាកលវិទ្យាល័យ ដើម្បីផ្តល់សេវា ជំនួយផ្នែកច្បាប់ និងសេវាកម្ម ច្បាប់ពាក់កណ្តាលមេធាវី ។

អង្គភាពសម្របសម្រួលសកម្មភាពជំនួយផ្នែកច្បាប់: អង្គភាពនេះត្រូវបានបង្កើតឡើងដើម្បីអភិវឌ្ឍ នូវយុទ្ធសាស្ត្រជាតិយូរអង្វែងក្នុងការផ្តល់សេវាជំនួយផ្នែកច្បាប់ ។

ការប្រមែប្រមូលធនធានហិរញ្ញវត្ថុ: វិភាគទានតិចតួចត្រូវបានរៃអង្គាសប្រមែប្រមូលបញ្ចូលក្នុង គណនីទូទៅមួយដើម្បីបំរើឲ្យសេវាជំនួយផ្នែកច្បាប់តាមអាទិភាពកំណត់ដែលមានការគ្រប់គ្រងយ៉ាងត្រឹមត្រូវ ។

វិស័យជំនួយផ្នែកច្បាប់នៃមេធាវីឯកជន: បង្កើតយន្តការទំនាក់ទំនងជាមួយមេធាវីក្នុងវិស័យឯកជន

ធ្វើទំនាក់ទំនងជាមួយផ្នែកឯកជន: ត្រូវមានកម្មវិធីទំនួលខុសត្រូវផ្នែកសង្គមរបស់សហគ្រាសដើម្បីឧបត្ថម្ភសកម្មភាពសេវាជំនួយផ្នែកច្បាប់ ។

បង្កើតខ្សែទូរសព្ទ័ និងប្រពន្ធ័ Skypeបន្ទាន់: ខ្សែទូរសព្ទ័បន្ទាន់ដែលមានស្រាប់គួរត្រូវបានជួយឧបត្ថម្ភ ឲ្យប្រសើរឡើង និងបង្កើតខ្សែទូរសព្ទ័បន្ទាន់តាមបណ្តាភូមិភាគ ព្រមទាំងមានបុគ្គលិកប្រចាំការណ៍ផង ។

ជំរើសសកម្មភាពជាក់លាក់: បង្កើតនូវកម្រងសកម្មភាពតូចៗដែលរាជរដ្ឋាភិបាលអាចអនុវត្តដើម្បីបង្កើនប្រសិទ្ធិភាពសេវាជំនួយផ្នែកច្បាប់ ។

## អនុសាសន៍

អនុសាសន៍ទាំងនេះតំណាងឲ្យទស្សនៈរបស់អ្នកសរសេរឯកសារ គឺមិនឆ្លុះបញ្ចាំងមតិរបស់រាជ រដ្ឋាភិបាល ឬក៏ទីភ្នាក់ងារជំនួយអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសដាណឺម៉ាកឡើយ ។ អនុសាសន៍ទាំងនេះធ្វើ

DRAFT

ឡើងក្នុងបរិបទដែលអាចប្រមើលបរិយាកាសនៃ**ជំនួយផ្នែកច្បាប់ ក្នុងប្រទេស កម្ពុជា សំរាប់រយៈពេល៥ ទៅ៧ឆ្នាំទៀត ។**

ដោយសារតែភាពមិនច្បាស់លាស់ជុំវិញស្ថានភាពថវិការបស់រាជរដ្ឋាភិបាលកម្ពុជា និងការកាត់បន្ថយជំនួយបរទេសក្នុងរយៈពេលមធ្យម ក្រុមអ្នកសរសេររបាយការណ៍សូមផ្តល់អនុសាសន៍នៃជំរើស ខាងក្រោម៖

លប់បំបាត់រនាំងឧបសគ្គ័ក្នុងការចូលរួមរបស់មេធាវីក្នុងជំនួយផ្នែកច្បាប់

លប់បំបាត់កត្តាអសកម្មដែលបណ្តាលឲ្យតំលៃសេវាជំនួយផ្នែកច្បាប់បច្ចុប្បន្នឡើងខ្ពស់

លើកទឹកចិត្តការចូលរួមពីតួរអង្គផ្សេងៗក្នុងវិស័យជំនួយផ្នែកច្បាប់

អនុសាសន៍ទាំងនេះក៏ធ្វើឡើងក្នុងការសន្មត់ថាការបង្កើនថវិការបស់រាជរដ្ឋាភិបាលលើវិស័យជំនួយផ្នែកច្បាប់ទៅបណ្តាស្ថាប័នរដ្ឋពាក់ពន្ធ័នៅមានកំរិតក្នុងរយៈពេលខ្លី ទៅរយៈពេលមធ្យម ។